**ភ្នាក់ងារក្រសួងសុខាភិបាលស្រុកអាឡាមីដា**
**ក្រសួងសាធារណៈសុខាភិបាល**

**Colleen Chawla,** អគ្គនាយក
**Kimi Watkins-Tartt,** អគ្គនាយក
**Nicholas J. Moss,** វេជ្ជបណ្ឌិត មន្ត្រី ស្ដីទីសុខាភិបាលស្រុក

www.acphd.org

---

**TO:** **ជូនចំពោះនិយោកជន(អ្នកជួល)ទាំងអស់នៅក្នុងស្រុកអាឡាមីដា**
**FROM:** **Nicholas J. Moss, MD, MPH, មន្ត្រីសុខភាពស្ដីទី**
**SUBJECT:** **មិនតម្រូវឲ្យមានលទ្ធផលអវិជ្ជមានរោគខូវីទ១៩ ដើម្បីត្រឡប់ចូលធ្វើការវិញ**

---

ក្រសួងសាធារណៈសុខាភិបាលស្រុកអាឡាមីដា(ACPHD) ប្ដេជ្ញារក្សាសុខភាព និងសុវត្ថិភាពជូនពលរដ្ឋគ្រប់រូបដែលរស់នៅ ឬប្រកបការងារនៅក្នុងស្រុកអាឡាមីដា។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះការគោរពប្រត្តិប័ត្រ របស់អ្នកទៅតាមសេចក្ដីតម្រូវសុវត្ថិភាពទីតាំងការងាររបស់ក្រសួងរដ្ឋ និងក្រសួងតំបន់ មានរួមទាំងការតម្រូវឲ្យពាក់ម៉ាស់ រក្សាគម្លាត៦ហ្វីត ឆែកសញ្ញារោគជាទៀងទាត់ និងផ្ដល់ជំនួយដល់បុគ្គលិកដែលឈឺសម្រាកនៅផ្ទះ។

រោគខូវីទ១៩ ជារោគរាលដាលនៅក្នុងសហគមន៍របស់យើង រូបអ្នកអាចមានបុគ្គលិកដែលមានរោគនេះ។ តាមបទបញ្ជាមន្ត្រីសុខាភិបាល ជនដែលមានរោគខូវីទ១៩ តម្រូវឲ្យសម្រាកនៅផ្ទះ នៅដាច់ដោយឡែកយ៉ាងហោច ណាស់ចំនួន១០ថ្ងៃ។ នៅកំណត់ថ្ងៃទី១១ បើគេមិនមានសីតុណ្ហភាព និងសញ្ញារោគផ្សេងៗ ទៀតបានគ្រាន់បើឡើង គេអាចឈប់នៅដាច់ដោយឡែក ហើយអាចត្រឡប់ចូលធ្វើការវិញបាន។ **ក្រសួងសាធារណៈសុខាភិបាលស្រុកអាឡាមីដា(ACPHD) សូមផ្ដល់សេចក្ដីណែនាំខ្ពង់ខ្ពស់ សូមឲ្យនិយោកជនអនុញ្ញាត្តិឲ្យបុគ្គលិកដែលមានរោគ ខូវីទ១៩ចូលធ្វើការវិញ បន្ទាប់ពីគេមានសញ្ញារោគចំនួន១០ថ្ងៃ (ឬតែស្តវិជ្ជមានលើកទី១ ដោយមិនមានសញ្ញារោគ)។**

ជនដែលនៅជិតស្និទជាមួយនិងជនមានរោគខូវីទ១៩ តម្រូវឲ្យនៅផ្ទះដាច់ដោយឡែកយ៉ាងហោចណាស់ចំនួន១៤ថ្ងៃ។ នៅកំណត់ថ្ងៃទី១៥ បើគេមិនមានសញ្ញារោគ គេអាចឈប់នៅដាច់ដោយឡែក ហើយអាចត្រឡប់ចូលធ្វើការវិញបាន។ **យើងសូមផ្ដល់សេចក្ដីណែនាំថា ចំពោះជនដែលបានបញ្ចប់ការនៅដាច់ដោយឡែក មិនតម្រូវឲ្យធ្វើ តែស្តអវិជ្ជមាន ទើបគេអាចត្រឡប់ចូលធ្វើការវិញបាននោះឡើយ។**

សេចក្ដីណែនាំនេះ ជាសេចក្ដីណែនាំទូទៅរបស់ក្រសួងសាធារណៈសុខាភិបាល យោងទៅតាមភស្តុតាងវិទ្យាសាស្ត្រ និងសេចក្ដីណែនាំរបស់ក្រសួងសាធារណៈសុខាភិបាលរដ្ឋកាលីហ្វ័រនីញ៉ា(CDPH) រួមនិងមណ្ឌលបង្ក្រាប ការពាររោគសហព័ន្ធ (CDC)។ ចំពោះជនដែលមានរោគវិជ្ជមាន ពុំចាំបាច់ធ្វើតែស្តឡើងវិញទេ វាមានអត្ថប្រយោជន៍តិចតួចបំផុតសំរាប់ផ្នែកពេទ្យ ភស្តុតាងបានបង្ហាញច្បាស់ថា ភាគច្រើនបន្ទាប់ពីចំនួន១០ថ្ងៃរោគនោះមិនអាចឆ្លងបានឡើយ។

ការពិនិត្យបញ្ជាក់តែស្តអវិជ្ជមានពុំមែនជាវិធីមានប្រសិទ្ធិភាពក្នុ ងការបញ្ជាក់ថាជននោះនៅតែអាចចម្លងរោគឡើយ តែស្តខ្លះរកឃើញមេរោគដែលងាប់ ក្រោយពីជននោះលែងចម្លងមេរោគជាច្រើនសប្តាហ៍មក។ ការពិនិត្យបញ្ជាក់ ធ្វើឲ្យប៉ះទង្គិចដល់ប្រព័ន្ធសុខាភិបាល ដោយអ្នកដែលត្រូវការធ្វើតែស្ត និងអ្នកដែលប្រកបដោយគ្រោះថ្នាក់អាក់ខានមិនបានធ្វើតែស្ត។ **ក្រសួងសាធារណៈសុខាភិបាលស្រុកអាឡាមីដា ACPHD ពុំចេញលិខិតពិនិត្យបញ្ជាក់ឲ្យចូលធ្វើការ ហើយក៏មិនចាំបាច់មានលិខិតពិនិត្យបញ្ជាក់ឲ្យចូលធ្វើការ ពីវេជ្ជបណ្ឌិត ឬពេទ្យឡើយ។**

សូមអរគុណចំពោះសហការរបស់លោកអ្នក និងតួនាទីដ៏សំខាន់ដែលរូបអ្នកចូលរួមរក្សាសហគមន៍របស់យើងប្រកបដោយសុវត្ថិភាព។

---

**Resources for additional information:**

- CDPH - https://www.cdph.ca.gov/Programs/CID/DCDC/Pages/COVID-19/Updated-COVID-19-Testing-Guidance.aspx
- សេចក្ដីណែនាំធ្វើតែស្ត
- CDC: https://www.cdc.gov/coronavirus/2019-ncov/hcp/disposition-in-home-patients.html
- អ្នកជម្ងឺតាមផ្ទះ

Colleen Chawla, អគ្គនាយក
Kimi Watkins-Tartt, អគ្គនាយក
Nicholas J. Moss, វេជ្ជបណ្ឌិត មន្ត្រី ស្តីទីសុខាភិបាលស្រុក



- ACPHD: http://www.acphd.org/media/568880/acphd-covid-19-release-from-iso-or-quar-and-return-to-work-criteria-english.pdf
- អនុញ្ញាត្តិឈប់នៅដាច់ដោយឡែក និងត្រឡប់ចូលធ្វើការវិញ